00401518

MS/AC (1) 235

ឯកសារទទួល
DOCUMENT RECEIVED/DOCUMENT REÇU
ថ្ងៃ ខែ ឆ្នាំ (Date of receipt/Date de reception): 05 / 11 / 2009
ម៉ោង (Time/Heure): 14:30
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: Ratanak

**នៅចំពោះមុខការិយាល័យសហចៅក្រមស៊ើបអង្កេត**
**អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា**

## ព័ត៌មានពិស្តារអំពីការដាក់ឯកសារ

សំណុំរឿងលេខ: ០០២/១៩-០៩-២០០៧-អ.វ.ត.ក-ក.ស.ច.ស

ភាគីដាក់ឯកសារ: សហមេធាវីរបស់លោក នួន ជា

ដាក់ជូន: សហចៅក្រមស៊ើបអង្កេត

ភាសាដើម: អង់គ្លេស

កាលបរិច្ឆេទឯកសារ: ថ្ងៃទី៥ ខែវិច្ឆិកា ឆ្នាំ ២០០៩

## <u>ចំណាត់ថ្នាក់ឯកសារ</u>

ចំណាត់ថ្នាក់ឯកសារ ស្នើឡើងដោយភាគីដាក់ឯកសារ: សាធារណៈ

សម្ងាត់ CONFIDENTIAL CONFIDENTIEL 12/11/2009

ចំណាត់ថ្នាក់ឯកសារដោយ កសចស

ពិនិត្យឡើងវិញចំពោះឯកសារចំណាត់ថ្នាក់ណ្តោះអាសន្ន:

ឈ្មោះមន្ត្រីកត់ត្រា:

ហត្ថលេខា:

សាធារណៈ PUBLIC 13/01/2010

---

## សំណើសុំបង្កើតវិធានការនីតិវិធីជាក់លាក់

---

<u>ដាក់ដោយ៖</u>

**សហមេធាវីរបស់លោក នួន ជា**

លោក សុន អរុណ

លោក Michiel PESTMAN

លោក Victor KOPPE

លោក Andrew IANUZZI

លោក Jasper PAUW

លោក ព្រំ ផល្លា

<u>ផ្ញើជូន៖</u>

**សហព្រះរាជអាជ្ញា:**

អ្នកស្រី ជា លាង

លោក William SMITH

**ក្រុមមេធាវីការពារក្តីទាំងអស់**

ឯកសារបានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម
CERTIFIED COPY/COPIE CERTIFIÉE CONFORME
ថ្ងៃ ខែ ឆ្នាំ នៃការបញ្ជាក់ (Certified Date/Date de certification): 14 / 01 / 2010
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: SANN RADA

## I. សេចក្តីផ្តើម

1. អនុលោមទៅតាមវិធាន ៥៥(១០) នៃវិធានផ្ទៃក្នុងរបស់ អវតក (“វិធានផ្ទៃក្នុង”) មេធាវីការពារក្តីជនត្រូវចោទ **នួន ជា** (“មេធាវីការពារក្តី”) សូមដាក់សំណើសុំបង្កើតវិធានការនីតិវិធីពិតប្រាកដនេះទៅការិយាល័យសហចៅក្រមស៊ើបអង្កេត (“កសចស”)។

## II. សាវតារអង្គហេតុ

2. អនុលោមទៅតាមវិធាន ៦៦ នៃវិធានផ្ទៃក្នុង (“វិធាន”) មេធាវីការពារក្តីយល់ឃើញថា វាជាបំណងរបស់ កសចស ក្នុងការជូនដំណឹងដល់ភាគីទាំងអស់មិនឲ្យលើសពីថ្ងៃទី៩ ខែធ្នូ ឆ្នាំ២០០៩ ថាកិច្ចស៊ើបសួរនៅក្នុងសំណុំរឿងលេខ 002/19-09-2007-ECCC/OCIJ បានបញ្ចប់។

3. មេធាវីការពារក្តីព្រួយបារម្ភថា ប្រព័ន្ធបច្ចុប្បន្នដែលផ្តល់ដោយវិធាន ៦៦ អាចប៉ះពាល់យ៉ាងធ្ងន់ធ្ងរដល់សិទ្ធិរបស់ជនត្រូវចោទ។ អាស្រ័យហេតុនេះ យើងសូមស្នើ កសចស ឲ្យបង្កើតវិធានការផ្នែកនីតិវិធីជាក់លាក់ ដើម្បីធានាថាសិទ្ធិរបស់ **នួន ជា** ត្រូវបានធានានៅទូទាំងដំណើរការនីតិវិធី។

4. ប្រព័ន្ធដែលបង្កើតដោយវិធាន ៦៦ អាចសង្ខេបដូចតទៅនេះ។ កសចស ត្រូវដាក់ការជូនដំណឹងពីការបញ្ចប់កិច្ចស៊ើបសួរ (“ការជូនដំណឹង វិធាន៦៦”)។ បន្ទាប់មកមេធាវីការពារក្តីមានរយៈពេល ១៥ថ្ងៃ ដើម្បីដាក់សំណើសុំឲ្យមានកិច្ចស៊ើបសួរបន្ថែម បន្ទាប់ពីទទួលការជូនដំណឹងនេះ។ ប្រសិនបើ កសចស សម្រេចបដិសេធលើសំណើទាំងនេះ សហចៅក្រមស៊ើបអង្កេតត្រូវចេញដីកាបដិសេធ។ បន្ទាប់មកមេធាវីការពារក្តីមានរយៈពេល៣០ថ្ងៃ ដើម្បីប្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចនេះ។ ដូចគ្នានេះដែរ កសចស ត្រូវចេញដីកាបដិសេធលើសំណើទាំងអស់ដែលមិនទាន់សម្រេច ហើយមេធាវីការពារក្តីមានរយៈពេល៣០ ថ្ងៃ ដើម្បីប្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចនេះ[1]។ នៅក្នុងបរិបទនេះ ត្រូវបានគេកត់សំគាល់ថា វាខុសពីវិធានផ្ទៃក្នុង ដែលថា កសចស អាចបន្ថែមភស្តុតាងទៅក្នុងសំណុំរឿងរហូតដល់ថ្ងៃដាក់ការជូនដំណឹងក្រោមវិធាន ៦៦ ។

5. នីតិវិធីនេះផ្តល់ឱកាសឲ្យ កសចស បង្កើតវិធីសាស្ត្រមួយឈានទៅរកការបញ្ចប់កិច្ចស៊ើបសួរ ដែលអាចប៉ះពាល់យ៉ាងធ្ងន់ធ្ងរដល់សិទ្ធិរបស់ **នួន ជា** ហើយវាក៏បង្កើតឲ្យមានដំណើរការស៊ើបសួរគ្មាន

---

[1] វិធាន ៦៦ នៃវិធានផ្ទៃក្នុង ។

ប្រសិទ្ធិភាពផងដែរ។ សំណើនេះមានបំណងដោះស្រាយ និង/ឬ ស្វែងរកដំណោះស្រាយទៅលើចំនុចខ្វះចន្លោះទាំងនេះ។

6. ជាពិសេស លទ្ធភាពដែល កសចស អាចធ្វើសេចក្តីសម្រេចលើសំណើមុនៗ ស្នើសុំបំពេញកិច្ចស៊ើបសួរ នៅពេលចេញការជូនដំណឹងក្រោមវិធាន៦៦ (ឬភ្លាមៗមុនពេលចេញការជូនដំណឹង) និង/ឬ លទ្ធភាពដែលកសចសបន្ថែមភស្តុតាងថ្មីទៅក្នុងសំណុំរឿងក្នុងពេលដំណាលគ្នាចេញការជូនដំណឹង (ឬភ្លាមៗមុនពេលចេញការជូនដំណឹង) គឺជាក្តីបារម្ភដ៏ធំធេងរបស់មេធាវីការពារក្តី ដោយសារតែទង្វើរបែបនេះអាចប៉ះពាល់យ៉ាងធ្ងន់ធ្ងរដល់សិទ្ធិរបស់ជនត្រូវចោទ។

7. តាមពិត មេធាវីការពារក្តីមិនដឹងថា កសចស គ្រោងនឹងធ្វើចំណាត់ការដោយរបៀបណាចំពោះពេលវេលាស៊ើបសួរដែលនៅសល់នោះទេ។ មេធាវីការពារក្តីមិនដឹងថាកសចស នឹងធ្វើការសម្រេចលើសំណើសុំបំពេញកិច្ចស៊ើបសួរនៅពេលណា ឬកសចស មានផែនការបន្ថែមលទ្ធផលចុងក្រោយនៃកិច្ចស៊ើបសួរទៅក្នុងសំណុំរឿងនៅពេលណានោះដែរ។ មេធាវីការពារក្តីមិនសន្មតថា កសចស នឹងធ្វើសកម្មភាពផ្ទុយពីសិទ្ធិរបស់ជនត្រូវចោទនោះទេ។ ហេតុដូច្នេះ សំណើនេះមិនត្រូវបានគេយល់ថាជាការរិះគន់ទៅលើវិធីសាស្ត្រដែលការិយាល័យរបស់លោកមានបំណងអនុវត្តនោះទេ។

8. ជាការពិត កសចស អាចសម្រេចរួចមកហើយ ដើម្បីអនុញ្ញាតឲ្យមានពេលវេលាគ្រប់គ្រាន់រវាងសេចក្តីសម្រេចលើសំណើមុនៗ និងការបន្ថែមឯកសារទៅក្នុងសំណុំរឿងម្យ៉ាង ហើយម្យ៉ាងទៀតការជូនដំណឹងពីការបញ្ចប់កិច្ចស៊ើបសួរ។ យ៉ាងណាក៏ដោយ កសចស តម្រូវឲ្យការពារផលប្រយោជន៍របស់ **នួន ជា**។ មេធាវីការពារក្តីពុំមានជម្រើសផ្សេងនោះទេ ប៉ុន្តែ សូមលើកបញ្ហានេះនៅពេលនេះ និងក្នុងទម្រង់នេះ។ ប្រសិនបើមេធាវីការពារក្តីជ្រើសយកវិធីសាស្ត្ររង់ចាំមើល នោះអាចជាការមួយយឺតពេលក្នុងការធ្វើសកម្មភាព។ សំណើនេះ និងគោលបំណងរបស់វា ត្រូវតែបានយល់ក្នុងន័យបែបហ្នឹង[2]។

9. អាស្រ័យហេតុនេះ មេធាវីការពារក្តីស្នើសុំ កសចស:

---

[2] តាមគំនិតនេះ កសចស មិនត្រូវបដិសេធសំណើនេះភ្លាមៗនោះទេ ឧទាហរណ៍ ជាមួយនឹងការអះអាងដែលថា សិទ្ធិរបស់ជនត្រូវចោទមិនត្រូវបានរំលោភនៅឡើយ តែការជូនដំណឹងក្រោមវិធាន ៦៦ មិនបានធ្វើនៅឡើយ។ ម្តងទៀត មេធាវីការពារគ្រាន់តែមិនអាចរង់ចាំក្នុងការដាក់សំណើនេះទេ។ តាមពិត វាមិនខុសប្លែកអ្វីទេការដែលដាក់សំណើនេះ បន្ទាប់ពីការជូនដំណឹង ដោយវានឹងត្រូវបានគេលើកមកពិភាក្សានៅពេលនោះ បើពិចារណាទៅលើបញ្ហានេះ ។

ក. ជូនដំណឹងដល់ភាគីទាំងអស់ឲ្យបានឆាប់បំផុត តាមតែអាចធ្វើបាន ក្នុងរយៈពេលយ៉ាងយូរបំផុត**ពីរ ខែ** មុនពេលដាក់ការជូនដំណឹងពីកាលបរិច្ឆេទពិតប្រាកដ ដែល កសចស មានផែនការដាក់ការជូនដំណឹង ក្រោមវិធាន ៦៦ ។

ខ. ដាក់បញ្ចូលលទ្ធផលថ្មី**ទាំងអស់**នៃការស៊ើបសួរទៅក្នុងសំណុំរឿង ក្នុងរយៈពេលយ៉ាងយូរបំផុត**ពីរ ខែ** មុនពេលដាក់ការជូនដំណឹងក្រោមវិធាន ៦៦។ ក្របខណ្ឌពេលវេលានេះគឺសំខាន់ចាំបាច់ ដើម្បីធានាដល់ការចូលរួមនៅក្នុងនីតិវិធីប្រកបដោយប្រសិទ្ធិភាពពីសំណាក់ជនជាប់ចោទ។

គ. សម្រេចលើសំណើសុំបំពេញកិច្ចស៊ើបសួរដែលមិនទាន់សម្រេចទាំងអស់ ក្នុងរយៈពេលយ៉ាងយូរបំផុត**ពីរខែ** មុនពេលដាក់ការជូនដំណឹងក្រោមវិធាន ៦៦។ ក្របខណ្ឌពេលវេលានេះ គឺសំខាន់ចាំបាច់ ដើម្បីធានាដល់ការចូលរួមនៅក្នុងនីតិវិធីប្រកបដោយប្រសិទ្ធិភាពពីសំណាក់ជនជាប់ចោទ។

ឃ. ឆ្លើយតបចំពោះសំណើនេះក្នុងរយៈពេលពីរ (២) សប្តាហ៍ បន្ទាប់ពីបានដាក់។

10. មានតែការបង្កើតនូវវិធានការទាំងនេះទេ ទើបមេធាវីការពារក្តីអាចដាក់បណ្តឹងឧទ្ធរណ៍ ពង្រាងសំណើសុំបំពេញកិច្ចស៊ើបសួរបន្ថែមប្រកបដោយប្រសិទ្ធិភាពបាន និងអាចរៀបចំសកម្មភាពរបស់ខ្លួនសម្រាប់ខែបន្តបន្ទាប់ និងដើម្បីការពារសិទ្ធិរបស់ **នួន ជា** ក្នុងការទទួលបានការជំនុំជម្រះក្តីដោយយុត្តិធម៌។

11. ខណៈវិធាន ៦៦ មិនបានផ្តល់នូវវិធានការខាងនីតិវិធីទាំងនេះ មេធាវីការពារក្តីសូមបញ្ជាក់ថាវាពិតជាមិនបានហាមឃាត់ កសចស ពីការអនុវត្តវិធានការនីតិវិធីទាំងនេះដែរ។ មានទឡ្ហីករណ៍ខ្លាំងជាប្រព័ន្ធ និងការជំនុំជម្រះក្តីដោយយុត្តិធម៌គាំទ្រដល់ការលើកឡើងទាំងនេះ ដែលនឹងពិភាក្សានៅខាងក្រោម។ ម្យ៉ាងវិញទៀត សំណើនេះនឹងលើកស្ទួយដល់សេដ្ឋកិច្ចតុលាការដែរ។

## III. **ច្បាប់ពាក់ព័ន្ធ**

12. មេធាវីការពារក្តី សូមដាក់បញ្ចូលសំណូមពរដែលមាននៅក្នុងសំណើមុនៗរបស់ខ្លួន ស្នើសុំឲ្យបំពេញកិច្ចស៊ើបសួរ។

13. ម្យ៉ាងវិញទៀត មេធាវីការពារក្តីសំអាងលើកិច្ចព្រមព្រៀង និង ច្បាប់បង្កើតអង្គជំនុំជម្រះវិសាមញ្ញជាពិសេស សិទ្ធិរបស់ **នួន ជា** ក្នុងការទទួលបានការជំនុំជម្រះក្តីដោយយុត្តិធម៌។ អនុលោមទៅ

តាមកិច្ចព្រមព្រៀង និង ច្បាប់បង្កើតអង្គជំនុំជម្រះវិសាមញ្ញ **នួន ជា** មានសិទ្ធិ "ទទួលបានពេលវេលា និង លក្ខណៈគ្រប់គ្រាន់ដើម្បីរៀបចំ [...] ការការពារខ្លួន"[3]។

14. តុលាការសិទ្ធិមនុស្សអឺរ៉ុប ដែលយុត្តិសាស្ត្ររបស់ស្ថាប័ននេះ ត្រូវបាន កសចស យកមកសំអាងកាលពីអតីតកាល បានផ្តល់ការបកស្រាយទូលំទូលាយមួយទៅលើទស្សនទាននៃ"ពេលវេលា និង លក្ខណៈគ្រប់គ្រាន់" នេះ៖

*តុលាការរំលឹកថាមាត្រា៦.៣ (ខ) ធានាជនជាប់ចោទ "មានពេលវេលា និងលក្ខណៈគ្រប់គ្រាន់សម្រាប់រៀបចំការការពារខ្លួន។ អាស្រ័យហេតុនេះ មានន័យថាសកម្មភាពការពារសំខាន់ដែលធ្វើឡើងជំនួសគាត់ អាចមានគ្រប់យ៉ាងដែល "ចាំបាច់" សម្រាប់រៀបចំសវនាការលើអង្គហេតុ។ ជនជាប់ចោទត្រូវតែមានឱកាសរៀបចំកិច្ចការពារខ្លួនគាត់ នៅក្នុងលក្ខណៈមួយដែលសមស្រប និងគ្មានការរឹតត្បិត ចំពោះលទ្ធភាពបង្ហាញទឡ្ហីករណ៍ការពារទាំងអស់នៅចំពោះមុខតុលាការ ដែលអាចមានឥទ្ធិពលដល់លទ្ធផលនីតិវិធី ។*

*ម្យ៉ាងវិញទៀត ជនទាំងឡាយណាដែលត្រូវបានចោទប្រកាន់ពីឧក្រិដ្ឋកម្មធ្ងន់ធ្ងរ ត្រូវទទួលបានពេលវេលា និងលក្ខណៈគ្រប់គ្រាន់ រួមមានឱកាសស្គាល់ពីគោលបំណងរៀបចំកិច្ចការពារខ្លួនគាត់ ជាមួយនឹងលទ្ធផលនៃការស៊ើបអង្កេតដែលត្រូវបានអនុវត្តនៅទូទាំងដំណើរការនីតិវិធី ។ បញ្ហាពេលវេលា និង លក្ខណៈគ្រប់គ្រាន់ដែលផ្តល់ទៅឲ្យជនជាប់ចោទ ត្រូវតែបានវាយតំលៃស្របតាមកាលៈទេសៈនៃករណីនីមួយៗ[4] ។*

សារៈសំខាន់ពិតៗនៃការវិភាគនេះ គឺថា "លទ្ធផលនៃកិច្ចស៊ើបសួរនៅទូទាំងដំណាក់កាលនៃដំណើរការនីតិវិធី" ត្រូវតែលាតត្រដាងនៅក្នុងលក្ខណៈមួយដែលធានាដល់សិទ្ធិការពារក្តី"ដែលអាចអនុវត្តបាន និងប្រកបដោយប្រសិទ្ធិភាព" ជាជាងសិទ្ធិដែលគ្រាន់តែជាទ្រឹស្តី និងការបំភាន់ភ្នែកនោះ[5]។

---

[3] មាត្រា ១៣(១) កិច្ចព្រមព្រៀង និង មាត្រា ៣៥ ថ្មី ច្បាប់បង្កើត អវតក ។

[4] ករណី *Galstyan* តទល់ជាមួយប្រទេសអាមេនី ECHR បណ្តឹងលេខ ២៦៩៨៦/០៣ កថាខណ្ឌទី ៨៤ នៃ "សាលក្រម" ចុះថ្ងៃទី ១៣ ខែវិច្ឆិកា ឆ្នាំ ២០០៧ (លុបសំអាង, បញ្ជាក់បន្ថែម)។

[5] ករណី *Artico* តទល់ជាមួយប្រទេសអ៊ីតាលី, ECHR បណ្តឹងលេខ ៦៦៩៤/៧៤ កថាខណ្ឌទី ៣៣ "សាលក្រម" ចុះថ្ងៃទី ១៣ ខែឧសភា ១៩៨០ ("នេះគឺជាសិទ្ធិរបស់ជនជាប់ចោទក្នុងការទទួលបានការជំនុំជម្រះក្តីដោយយុត្តិធម៌ នៅទីកន្លែងក្នុងសង្គមប្រជាធិបតេយ្យ")។ សូមមើលឯកសារ D130/11 សំណើលើកទី ១៥ ស្នើសុំបំពេញកិច្ចស៊ើបសួររបស់ក្រុមការពារក្តី នួន ជា ចុះថ្ងៃទី ១ ខែកញ្ញា ២០០៩។

15. មេធាវីការពារក្ដីនឹងពន្យល់នៅក្នុងសំណើនេះថា តើសិទ្ធិរបស់ជនត្រូវចោទនឹងត្រូវបានប៉ះពាល់យ៉ាងដូចម្ដេច បើសិន កសចស សម្រេចលើសំណើសុំបំពេញកិច្ចស៊ើបសួរដែលមិនទាន់បានដោះស្រាយ នៅពេលដាក់ការជូនការជូនដំណឹងលើវិធាន៦៦ (ឬភ្លាមៗនៅមុនរយៈពេលហ្នឹង) និង/ឬបន្ថែមភស្តុតាងទៅក្នុងសំណុំរឿងកៀកពេលដាក់ការជូនដំណឹង។ មេធាវីការពារនឹងបង្ហាញថា នៅក្នុងស្ថានការបែបនេះ ខ្លួននឹងមិនមានមធ្យោបាយដ៏មានប្រសិទ្ធិភាពដើម្បីមានឥទ្ធិពលលើលទ្ធផលនៃដំណើរការនីតិវិធីនោះទេ" ហេតុដូច្នេះ សិទ្ធិរបស់ជនជាប់ចោទគ្រាន់តែជាទ្រឹស្ដី និងជាការបំភាន់ភ្នែកតែប៉ុណ្ណោះ"។

16. ការបញ្ចប់ការស៊ើបសួរនៅពេលវេលាសមស្របគឺជាគោលបំណងដែលគួរឲ្យកោតសរសើរ ហើយក៏ជាផលប្រយោជន៍របស់ជនត្រូវចោទផងដែរ។ ប៉ុន្តែ ការប្រាថ្នាបញ្ចប់កិច្ចស៊ើបសួរនេះ មិនត្រូវធ្វើឲ្យប៉ះពាល់ដល់សិទ្ធិរបស់ជនត្រូវចោទនោះទេ ដោយបញ្ចប់ការស៊ើបសួរយ៉ាងប្រញាប់ប្រញាល់។ វិធីសាស្ត្របែបមិនត្រឹមតែដើរផ្ទុយពីលក្ខខណ្ឌតម្រូវនៃការជំនុំជម្រះក្ដីដោយយុត្តិធម៌ទេ តែថែមទាំងបង្កអោយមានហានិភ័យក្នុងការពន្យារនីតិវិធីសវនាការទៀតផង។

17. ដូចដែលត្រូវបានគេដឹងឮរួចមកហើយ មេធាវីការពារក្ដីមិនមានឱកាសច្រើនទេ ដើម្បីធ្វើការស៊ើបអង្កេតដោយខ្លួនឯង នៅក្នុងប្រព័ន្ធស៊ើបសួរដែលអនុម័តដោយអ្នកព្រាងវិធានផ្ទៃក្នុង។ កសចស ខ្លួនឯងបានសម្រេចថា មេធាវីការពារក្ដីត្រូវហាមឃាត់ពីការស៊ើបសួរដោយខ្លួនឯង[6]។ ស្ថិតនៅក្រោមកាលៈទេសៈនេះ កិច្ចស៊ើបសួរត្រូវតែធ្វើឡើងដោយយកចិត្តទុកដាក់ជាទីបំផុត, សិទ្ធិរបស់ជនត្រូវចោទត្រូវតែបានគោរពយ៉ាងពេញលេញ និងត្រូវបានការពារនៅទូទាំងដំណើរការនីតិវិធី ។

18. កសចស បានទទួលស្គាល់យ៉ាងច្បាស់ពីសារសំខាន់នៃការអនុវត្តសិទ្ធិ*ប្រកបដោយប្រសិទ្ធិភាព* ដើម្បីដាក់សំណើសុំបំពេញកិច្ចស៊ើបសួរ ទោះបីជានៅក្នុងអត្ថបទខុសគ្នាបន្តិចក៏ដោយ[7]។ វាច្បាស់ណាស់ថា សិទ្ធិដើម្បីដាក់សំណើសុំបំពេញកិច្ចស៊ើបសួរអាចត្រូវបានអនុវត្តដោយគ្មានប្រសិទ្ធិភាព

---

[6] ឯកសារ A 110/1ចម្លើយតបចំពោះលិខិតរបស់លោក ចុះថ្ងៃទី ២០ ខែ ធ្នូ ២០០៧ ទាក់ទងនឹងការស៊ើបសួរ ចុះថ្ងៃទី១០ ខែ មករា ២០០៨ ទំព័រ ២ ("អំណាចស៊ើបសួរនៅចំពោះមុខតុលាការនេះ គឺត្រូវបានប្រគល់ឲ្យតែសហចៅក្រមស៊ើបអង្កេតឯករាជ្យទាំងពីររូប ហើយមិនប្រគល់ទៅអោយភាគីទេ")។

[7] ដូចខាងលើ ទំព័រ២ ("សមត្ថភាពរបស់ភាគីដើម្បីអន្តរាគមន៍ ត្រូវបានដាក់កម្រិតយ៉ាងតឹងរឹង ត្រឹមតែការស៊ើបសួរបឋម ដែលចាំបាច់សម្រាប់ការអនុវត្តសិទ្ធិពួកគេប្រកបដោយប្រសិទ្ធិភាព ចំពោះសំណើសុំបំពេញកិច្ចស៊ើបសួរតែប៉ុណ្ណោះ" (បញ្ជាក់បន្ថែម)

ប្រសិនបើពេលវេលាដែលផ្តល់ទៅឱ្យភាគីដើម្បីដាក់សំណើបន្ថែម ផ្អែកតាមភស្តុតាងថ្មី ឬសម្រាប់ដាក់បណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចលើកមុនៗ មិនគ្រប់គ្រាន់។

19. តាមរយៈនេះ មេធាវីការពារក្តីសំអាងលើវាក្យសព្ទនៃវិធាន២១(១)នៃវិធានផ្ទៃក្នុង[8]។ ពាក្យសព្ទនេះមានន័យយ៉ាងច្បាស់ថា ក្នុងចំណោមបញ្ហាដទៃទៀត ភាពគ្មានមន្ទិលសង្ស័យផ្នែកច្បាប់ និងតម្លាភាពរបស់ដំណើរការនីតិវិធី គឺមានសារៈសំខាន់ជាទីបំផុតនៅទូទាំងដំណើរការនីតិវិធី។ ភាពគ្មានមន្ទិលសង្ស័យផ្នែកច្បាប់ និងតម្លាភាពរបស់ដំណើរការនីតិវិធីអាចសម្រេចបាន ប្រសិនបើទម្រង់នានានៅជុំវិញការបញ្ចប់កិច្ចស៊ើបសួរ ត្រូវបានអនុវត្តនៅក្នុងលក្ខណៈមួយដែលការពារសិទ្ធិរបស់ជនត្រូវចោទ។ ក្នុងន័យម្យ៉ាងទៀត របៀបនៃការជូនដំណឹងពីការបញ្ចប់កិច្ចស៊ើបសួរ នឹងត្រូវបានផ្សព្វផ្សាយ ហើយការជូនដំណឹងនេះ មិនត្រូវបានគេបកស្រាយថា សិទ្ធិរបស់ជនត្រូវចោទដើម្បីចូលរួមយ៉ាងប្រសិទ្ធិភាពក្នុងនីតិវិធី "គ្រាន់ជាទ្រឹស្តី និងជាការបំភាន់ភ្នែកនោះទេ"។

## IV. ឧឡារិករណ៍

20. សំណើនេះលើកឡើងនូវបញ្ហាបួន ដែលជាបញ្ហាដល់មេធាវីការពារក្តី: (i) សំណើសុំបំពេញកិច្ចស៊ើបសួរដ៏ច្រើនដែល កសចស មិនទាន់សម្រេចនៅឡើយ, (ii) រយៈពេល១៥ ថ្ងៃសម្រាប់ដាក់សំណើបន្ថែម ស្របតាមវិធាន ៦៦, (iii) បញ្ហាដែលកើតឡើងចំពោះមេធាវីការពារក្តីបណ្តាលមកពីភាពមិនប្រាកដប្រជានៃកាលបរិច្ឆេទបញ្ចប់ការស៊ើបសួរ និង (iv) ភាពមិនអាចបកប្រែឱ្យបានត្រឹមត្រូវនូវឯកសារទាំងអស់ដែលត្រូវបានដាក់ក្នុងរយៈពេលខ្លីបែបនេះ។ បន្ទាប់ពីការពិភាក្សាលើបញ្ហាទាំងនេះ សំណើនេះនឹងពិពណ៌នាដោយសង្ខេបពីសាវតាររបស់ប្រព័ន្ធ ដូចដែលបានអនុម័តនៅក្នុងវិធានផ្ទៃក្នុងនេះ។ ជាបន្ទាប់ សំណើនេះនឹងបញ្ចប់ជាមួយការពិចារណាជាប្រព័ន្ធ ដែលនឹងបង្ហាញឱ្យឃើញថា សំណើរបស់យើងគឺស្របជាមួយប្រព័ន្ធស៊ើបសួរ ដែលអ្នកពង្រាងវិធានផ្ទៃក្នុងត្រូវតែបានដឹង។

### ក. សំណើសុំបំពេញកិច្ចស៊ើបសួរដែលមិនទាន់សម្រេច

21. ដូចបានរៀបរាប់រួចមកហើយ វិធាន ៦៦ អនុញ្ញាតឱ្យ កសចស សម្រេចលើសំណើសុំបំពេញកិច្ចស៊ើបសួរដែលមិនទាន់សម្រេច រហូតដល់ការដាក់ការជូនដំណឹងពីការបញ្ចប់កិច្ចស៊ើបសួរ ត្រូវបាន

[8] វិធាន ២១(១)។

ផ្សព្វផ្សាយ ("ការជូនដំណឹងក្រោមវិធាន ៦៦")[9]។ តាមពិត បើសិន កសចស បង្កើតនូវចំណាត់ការបែបនេះ នោះមេធាវីការពារក្ដីនឹងប្រឈមមុខជាមួយបញ្ហាអនុវត្តដ៏ច្រើន ដែលឈានទៅរកការរំលោភលើសិទ្ធិទទួលបានការជំនុំជម្រះក្ដីដោយយុត្តិធម៌របស់កូនក្ដីយើងខ្ញុំ។ ក្នុងស្ថានការណ៍នេះ មេធាវីការពារក្ដីនឹងត្រូវបានច្រានចេញពីការដាក់បណ្ដឹងឧទ្ធរណ៍ប្រកដោយប្រសិទ្ធិភាព ប្រឆាំងនឹងការបដិសេធរបស់ កសចស ក្នុងការអនុវត្តលើសំណើសុំបំពេញកិច្ចស៊ើបសួររបស់ខ្លួន ជាពុំខានឡើយ។

22. បច្ចុប្បន្ននេះ មេធាវីការពារក្ដីមានសំណើសុំបំពេញកិច្ចស៊ើបសួរជាច្រើន មិនទាន់បានសម្រេចនៅឡើយ។ វាមិនទាន់ដឹងច្បាស់នៅឡើយថា តើមានសំណើចំនួនប៉ុន្មាននឹងសម្រេចដោយការិយាល័យរបស់លោក នៅមុនការជូនដំណឹងពីការបញ្ចប់កិច្ចស៊ើបសួរក្រោមវិធាន ៦៦ នេះ។ ប៉ុន្តែ ក្នុងករណីដែល កសចស សម្រេចលើសំណើមុនៗទាំងនេះ តែនៅពេលដាក់ការជូនដំណឹងពីការបញ្ចប់កិច្ចស៊ើបសួរ (ឬភ្លាមៗមុនរយៈពេលហ្នឹង) នោះមេធាវីការពារក្ដីនឹងប្រឈមមុខជាមួយភាពមិនអាចអនុវត្តបាននូវការដាក់បណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងសេចក្ដីសម្រេចទាំងអស់នោះបានឡើយ។

23. វាមិនពិបាកក្នុងការយល់ដឹងពីភាពមិនអាចអនុវត្តបាននេះទេ។ អនុលោមទៅតាមវិធាន៧៥ មេធាវីការពារក្ដីតម្រូវឲ្យដាក់សារណាបណ្ដឹងឧទ្ធរណ៍ក្នុងរយៈពេល៣០ថ្ងៃ ទាក់ទងទៅនឹងការបដិសេធសំណើសុំបំពេញកិច្ចស៊ើបសួរ[10]។ ដើម្បីឲ្យអង្គបុរេជំនុំជម្រះពិចារណា សារណាបណ្ដឹងឧទ្ធរណ៍ត្រូវបញ្ជាក់ពីអំណះអំណាងខាងអង្គហេតុ និងអង្គច្បាប់ដែលពាក់ព័ន្ធ ព្រមទាំងភ្ជាប់ជាមួយឯកសារសំអាងផងដែរ[11]។

24. កិច្ចការពង្រាងបណ្ដឹងឧទ្ធរណ៍ទាំងនេះ គួបផ្សំជាមួយកិច្ចការដទៃទៀតដែលតម្រូវដោយវិធាន ៦៦ (ការដាក់សំណើបន្ថែមស្នើសុំបំពេញកិច្ចស៊ើបសួរក្នុងរយៈពេល១៥ថ្ងៃ, សូមមើលខាងក្រោម) គឺពិតជាមិនអាចធ្វើទៅរួចនោះទេ បើសិន កសចស សម្រេចលើសំណើ(ជាច្រើន) ដែលមិនទាន់

---

[9] តាមពិត កសចស អាចពន្យារពេលសេចក្ដីសម្រេចលើសំណើទាំងនេះ រហូតដល់ពេលចេញដីកាសម្រេច ("ដីកា, វិធាន ៦៦(២)") ដែលខ្លួនសម្រេចលើសំណើបន្ថែមដែលត្រូវបានដាក់ បន្ទាប់ពីការជូនដំណឹងក្រោមវិធាន ៦៦ ។ ចំណាត់ការបែបនេះ អាចនឹងបង្កើតបញ្ហាធ្ងន់ធ្ងរមកលើមេធាវីការពារ សូមមើលខាងក្រោម។

[10] វិធាន ៧៥។

[11] វិធាន ៧៥(៤) "សារណារបណ្ដឹងឧទ្ធរណ៍ត្រូវបញ្ជាក់ពីអំណះអំណាងខាងអង្គហេតុ និងអង្គច្បាប់ ដែលជាមូលដ្ឋាននៃបណ្ដឹងឧទ្ធរណ៍ ដោយភ្ជាប់ជាមួយនូវឯកសារសំអាងទាំងនោះ។ ម្ចាស់បណ្ដឹងឧទ្ធរណ៍មិនអាចលើកក្នុងពេលសវនាការ បញ្ហាអង្គហេតុ ឬអង្គច្បាប់ ដែលមិនមានចែងនៅក្នុងសារណាបណ្ដឹងឧទ្ធរណ៍នោះឡើយ")។

សម្រេច តែនៅពេលដាក់ការជូនដំណឹង ក្រោមវិធាន៦៦ ឬភ្លាមៗមុនរយៈពេលហ្នឹង។ បើនិយាយឲ្យចំទៅ វាពិតជាមិនអាចធ្វើបានឡើយសម្រាប់មេធាវីការពារក្តី ដើម្បីដាក់សារណាបណ្តឹងឧទ្ធរណ៍ឲ្យបានច្រើនជាងចំនួនកំណត់ ក្នុងរយៈពេល៣០ ថ្ងៃនេះ ។

## *១ ពុំអាចរៀបចំប្រកបដោយប្រសិទ្ធិភាពបាននោះទេ*

25. មេធាវីការពារក្តី មិនអាចរៀបចំខ្លួនឲ្យបានសមស្របសម្រាប់ធ្វើបណ្តឹងឧទ្ធរណ៍ទាំងនេះបានទេ ដោយសារតែខ្លួនមិនមានមធ្យោបាយណាដើម្បីឲ្យដឹងថា សំណើមួយណាអាចត្រូវបានបដិសេធ ហើយដោយមូលហេតុអ្វីនោះ។ មេធាវីការពារក្តីអាចចាប់ផ្តើមការងាររបស់ខ្លួនបាន តែនៅពេលដីកាសម្រេចរបស់ កសចស ត្រូវបានផ្សព្វផ្សាយប៉ុណ្ណោះ។

## *២ ការពន្យារពេលវេលាកំណត់ មិនមែនជាដំណោះស្រាយគ្រប់គ្រាន់នោះទេ*

26. ការដែលថា មានលទ្ធភាពដើម្បីស្នើសុំការពន្យារពេលវេលាកំណត់ដើម្បីដាក់បណ្តឹងឧទ្ធរណ៍ ស្របតាមវិធាន ៧៥(៣) មិនបានធ្វើឲ្យទឡ្ហីករណ៍របស់យើងចុះខ្សោយទេ។ ក្រោមកាលៈទេសៈ ដូចរៀបរាប់នៅខាងលើ លទ្ធភាពស្នើសុំពន្យារពេលវេលាកំណត់ មិនមែនជាដំណោះស្រាយគ្រប់គ្រាន់នោះទេ។

27. ជាបឋម សូមកត់សំគាល់ថា យុត្តិសាស្ត្ររបស់អង្គបុរេជំនុំជម្រះបានបញ្ជាក់យ៉ាងច្បាស់ថា មេធាវីការពារក្តីមិនអាចស្នើសុំពន្យារពេលវេលាកំណត់*ជាមុន*បានទេ។ នៅក្នុងសេចក្តីសម្រេចរបស់ខ្លួនចុះថ្ងៃទី៤ ខែកញ្ញា ឆ្នាំ២០០៩ នៅក្នុងករណីជនត្រូវចោទ អៀង ធិរិទ្ធ អង្គបុរេជំនុំជម្រះប្រកាសថា សំណើសុំរបស់ កសព ស្នើសុំពន្យារពេលដើម្បីឆ្លើយតបចំពោះសារណាបណ្តឹងឧទ្ធរណ៍របស់ជនត្រូវចោទ គឺធ្វើឡើងដោយប្រញាប់ប្រញាល់ពេក ដោយសារតែពេលវេលាកំណត់សម្រាប់ កសព ដើម្បីឆ្លើយតប "មិនទាន់ផុតពេលនៅឡើយ")[12]។ នេះមានន័យថា នៅក្នុងករណីរបស់យើង មេធាវីការពារក្តីមិនអាចដាក់សំណើទៅអង្គបុរេជំនុំជម្រះ ស្នើសុំការពន្យារពេលកំណត់ដើម្បីដាក់បណ្តឹងឧទ្ធរណ៍ មុនការផ្តល់ដំណឹងពិតប្រាកដដោយ កសចស អំពីលទ្ធភាពនៃការបដិសេធសំណើសុំបំពេញកិច្ចស៊ើបសួររបស់ខ្លួនបានឡើយ។

---

[12] ឯកសារ D130/9/5 សេចក្តីសម្រេចលើសំណើរបស់ កសព ស្នើសុំពន្យារពេលកំណត់ដើម្បីដាក់ចម្លើយ ចុះថ្ងៃទី ៤ ខែ កញ្ញា ២០០៩ កថាខណ្ឌទី៣។

28. ទី២ នៅចំនុចនេះមេធាវីការពារក្ដី មិនអាចចាត់វិធានការឲ្យទាន់ពេលក្រោមការសន្មតដែលថា សំណើសុំពន្យារពេលនឹងត្រូវអនុញ្ញាតនៅពេលក្រោយ។ តាមពិត សំណើសុំពន្យារពេលអាចត្រូវបដិសេធដោយអង្គបុរេជំនុំជម្រះ ដោយមូលហេតុជាច្រើន។ ម្យ៉ាងវិញទៀត បើទោះបីសំណើសុំពន្យារពេលនេះត្រូវបានអនុញ្ញាត ក៏នីតិវិធីសម្រាប់ពិចារណាលើសំណើនឹងប្រើរយៈពេលយ៉ាងតិចជាច្រើនថ្ងៃ ឬច្រើនសប្ដាហ៍ដែរ។ ក្នុងរយៈពេលមិនប្រាកដប្រជាបែបនេះ មេធាវីការពារក្ដីគ្មានជម្រើសនោះទេ ប៉ុន្តែត្រូវបន្តពង្រាងបណ្ដឹងឧទ្ធរណ៍ ដែលត្រូវប្រើពេលវេលាយ៉ាងច្រើន។

29. ជាសង្ខេប ការពិចារណាទាំងនេះនាំទៅរកការសន្និដ្ឋានថា លទ្ធភាពនៃការស្នើសុំពន្យារពេលកំណត់មិនមែនជាដំណោះស្រាយគ្រប់គ្រាន់នោះទេក្រោមកាលៈទេសៈនេះ។ អាស្រ័យហេតុនេះ មេធាវីការពារក្ដី ត្រូវបានច្រានចេញពីការដាក់បណ្ដឹងឧទ្ធរណ៍ទៅលើសេចក្ដីសម្រេចដាក់លាក់ ឬសេចក្ដីសម្រេចទាំងអស់ ដែលខ្លួនចង់ប្ដឹងជំទាស់។

## *៣. លទ្ធភាពនៃការសម្រេចលើសំណើដែលមិនទាន់សម្រេច នៅពេលដាក់ដីកាជូនដំណឹងក្រោមវិធាន ៦៦(២)*

30. ដូចបានលើកឡើង វិធានផ្ដល់លទ្ធភាពដើម្បីសម្រេចលើសំណើថ្មីៗដែលមិនទាន់សម្រេច នៅពេលដំណាលគ្នានឹងការសម្រេចលើសំណើបន្ថែម ដែលដាក់ក្នុងរយៈពេល១៥ ថ្ងៃបន្ទាប់ពីទទួលការជូនដំណឹងក្រោមវិធាន៦៦ ("ដីកា, វិធាន ៦៦(២)")[13]។ ការសម្រេចនៅដំណាក់កាលនេះ អាចចាត់ជា "ការបដិសេធ" លើសំណើទាំងអស់នេះទៅវិញទេ នេះបើតាមវាក្យសព្ទមាត្រា ៦៦(២)។ វាពិតណាស់ថា វិធីសាស្ត្របែបនេះនឹងផ្ដល់ឲ្យមេធាវីការពារក្ដីនូវពេលវេលាបន្ថែមច្រើនបន្តិច ជាងវិធីសាស្ត្របញ្ជូនសេចក្ដីសម្រេចតំណាលគ្នានឹងការដាក់ការជូនដំណឹងក្រោមវិធាន ៦៦ (ឬភ្លាមៗមុនរយៈពេលហ្នឹង) តែវិធីសាស្ត្រនេះនៅតែជាបញ្ហាដល់មេធាវីការពារក្ដីដដែល។

31. ជាបឋម បើតាមវិធីសាស្ត្រនេះ មេធាវីការពានឹងមិនដឹងពីលទ្ធផលនៃសំណើសុំបំពេញកិច្ចស៊ើបសួររបស់ខ្លួនបានទេ រហូតដល់ដំណាក់កាលចុងក្រោយបង្អស់នៃដំណើរការនីតិវិធី[14]។ មេធាវីការពារក្ដីពិតជាមិនចង់បាននូវលទ្ធផលបែបនេះទេ ជាពិសេស បើពិចារណាពីការចូលរួមដ៏មានប្រសិទ្ធិភាពពីសំណាក់ជនជាប់ចោទនៅដំណាក់កាលស៊ើបសួរ និងលទ្ធភាពរបស់ខ្លួនដើម្បីមានឥទ្ធិពលទៅលើ

---

[13] វិធាន ៦៦(២)។

[14] មេធាវីការពារក្ដីនឹងមិនដឹងពីខ្លឹមសាររបស់សេចក្ដីសម្រេច រហូតដល់ពេលដាក់ការជូនដំណឹងក្រោម វិធាន ៦៦ ។ បន្ទាប់ការជូនដំណឹង កសចស អាច "បដិសេធ" សំណើទាំងនេះ- មិនអនុញ្ញាត។

លទ្ធផលនីតិវិធី។ ម្យ៉ាងវិញទៀត ការពន្យារពេលបែបនេះនឹងមិនអាចធ្វើយុត្តិកម្មបានឡើយ។បន្ទាប់មក បើសិនជា កសចស មិនសម្រេចលើសំណើដែលមិនទាន់សម្រេច នៅពេលចេញដីកាក្រោមវិធាន ៦៦(២) នោះទេ បើតាមនិយមន័យ ដីកាសម្រេច គឺជា*សេចក្តីសម្រេចអវិជ្ជមាន*។ មិនមានមូលហេតុបង្ខិតបង្ខំថាហេតុអ្វីបានជាសេចក្តីសម្រេចអវិជ្ជមាននេះ មិនអាចជូនដំណឹងមក មេធាវីការពារក្តី នៅដំណាក់កាលដំបូងនោះទេ[15]។ ម្យ៉ាងវិញទៀត ដោយសារតែ កសចស ដឹងជាមុនថា កសចស នឹងមិនសម្រេចលើសំណើជាក់លាក់ កសចស ត្រូវតែជូនដំណឹងពីសេចក្តីសម្រេចបែបនេះឲ្យបានឆាប់បំផុត តាមដែលអាចធ្វើបាន[16]។ វិធីសាស្ត្របែបនេះ គឺជាអាជ្ញាបញ្ញា ដោយសារតែសេចក្តីសម្រេចបែបនេះ រួមទាំងពេលវេលានៃការចេញសេចក្តីសម្រេចនេះ អាចប៉ះពាល់ដល់លទ្ធភាពរបស់មេធាវីការពារក្តី ដើម្បីមានឥទ្ធិពលលើលទ្ធផលនៃដំណើរការនីតិវិធី។

32. ទី២ មេធាវីការពារក្តីប្រហែលចង់ពិចារណាឡើងវិញនូវយុទ្ធសាស្ត្ររបស់ខ្លួន និង/ឬធ្វើសេចក្តីសម្រេចសំខាន់ៗ បន្ទាប់ពីការចេញដីកាសម្រេចបដិសេធលើសំណើដោយ កសចស។ ដើម្បីឲ្យប្រាកដ ការដាក់បណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងសេចក្តីសម្រេចបែបនេះ គឺជាវិធានការមួយដែលមេធាវីការពារក្តីអាចជ្រើសយក។ មេធាវីការពារក្តីក៏អាចសម្រេចដាក់សំណើកែប្រែមួយ ស្នើសុំបំពេញកិច្ចស៊ើបសួរ ឬសំណើមួយដែលមិនមានចរិតលក្ខណៈជាសំណើសុំបំពេញកិច្ចស៊ើបសួរ ប៉ុន្តែមានចរិតលក្ខណៈជានីតិវិធី។ ពិតណាស់ ការសម្រេចរបស់មេធាវីការពារក្តីបែបនេះ អាចទទួលឥទ្ធិពលពីវាក្យសព្ទនៃដីកាសម្រេចបដិសេធមានសំអាងហេតុរបស់ កសចស។ ប៉ុន្តែ បើសិន កសចស ជូនដំណឹងពីដីកាសម្រេចបដិសេធ តែនៅពេលចេញដីកាក្រោមវិធាន ៦៦(២) នោះមេធាវីការពារក្តីនឹងត្រូវបានច្រានចេញពីការពិចារណាជំហានបន្ថែមទាំងនេះ នោះវានឹងគ្មានឱកាសដាក់សំណើបន្ថែម ឬ សំណើកែប្រែនោះទេ។ មេធាវីការពារក្តីត្រូវបានច្រានចេញពីការចូលរួមយ៉ាងសកម្មនៅក្នុងដំណើរការនីតិវិធីនៅដំណាក់កាលស៊ើបសួរ ដែលនាំឲ្យរំលោភដល់សិទ្ធិរបស់កូនក្តីក្នុងការទទួលបានការកាត់ក្តីដោយយុត្តិធម៌។

---

[15] ដើម្បីច្បាស់ សម្គាល់ពេលវេលាមិនផ្តល់ហេតុផលបង្ខិតបង្ខំដូចនេះទេ ព្រោះតែកាលកំណត់ដែល កសចស ធ្វើការគឺក្រោមការកំណត់លើដោយខ្លួនឯង។

[16] តាមពិតការជូនដំណឹងបែបនេះ មិនត្រូវតែធ្វើឡើងនៅភ្លាមៗមុនពេល ឬក្នុងពេលការជូនដំណឹងលើវិធាន៦៦នោះទេ។ សូមមើលហេតុផលក្នុងផ្នែកផ្សេងទៀតក្នុងសំណើ។

33. ទី៣ ក្នុងករណី កសចស សម្រេចលើសំណើសុំបំពេញកិច្ចស៊ើបសួរមួយចំនួន នៅដំណាលគ្នានឹងពេលចេញដីកាក្រោមវិធាន ៦៦(២) នោះមេធាវីការពារក្តីជាថ្មីម្តងទៀត នឹងប្រឈមមុខជាមួយភាពមិនអាចអនុវត្តបាន ដូចជាការដាក់បណ្តឹងឧទ្ធរណ៍សំខាន់ៗមួយចំនួនក្នុងរយៈពេលដ៏ខ្លី ដូចបានរៀបរាប់នៅក្នុងកថាខណ្ឌទី ២៣ ដល់ ២៩ ខាងលើ។

## ខ. រយៈពេល ១៥ ថ្ងៃ នៃវិធាន ៦៦(១)

34. ភាពស្មុគស្មាញបន្ថែមទៀតដល់មេធាវីការពារក្តី គឺថេរៈវេលា១៥ ថ្ងៃសម្រាប់ដាក់សំណើសុំបំពេញស៊ើបសួរបន្ថែម ស្របតាមវិធាន ៦៦។ មេធាវីការពារក្តីត្រូវតែបានដឹងពីភស្តុតាងទាំងអស់នៅក្នុងសំណុំរឿង ដើម្បីអាចធ្វើការសម្រេចថា តើខ្លួនចង់ឲ្យមានការស៊ើបសួរបន្ថែមដោយ កសចស ដែរឬយ៉ាងណានោះ។

35. ដូចបានពិពណ៌នារួចមកហើយ ប្រព័ន្ធច្បាប់ដែលនៅជាធរមាន អនុញ្ញាតឲ្យ កសចស ផ្តល់ដល់មេធាវីការពារក្តីនូវលទ្ធផលមួយចំនួន ឬលទ្ធផលទាំងអស់នៃការស៊ើបសួររបស់ខ្លួន (រួមទាំងភស្តុតាងដែលបានមកពីការស៊ើបសួរ តាមរយៈសំណើលើកមុនៗ ស្នើសុំបំពេញកិច្ចស៊ើបសួរផងដែរ) *តែនៅពេល*ដាក់ការជូនដំណឹងក្រោមវិធាន ៦៦ (ឬភ្លាមៗនៅមុនរយៈពេលហ្នឹង)។ ក្នុងស្ថានការបែបនេះ មេធាវីការពារក្តីនឹងមានពេលតិចជាង១៥ ថ្ងៃ ដើម្បីដាក់សំណើសុំបំពេញកិច្ចស៊ើបសួរបន្ថែម បើផ្អែកលើភស្តុតាង "ថ្មីៗ" ទាំងនោះ។

36. វិធីសាស្ត្របែបនេះដាក់បន្ទុកមកលើមេធាវីការពារក្តីនូវកិច្ចការដ៏លំបាក ដើម្បីសិក្សាភស្តុតាងថ្មីៗដ៏ច្រើនក្រាស់ក្រែងនៅក្នុងរយៈពេល១៥ថ្ងៃ ហើយក្នុងរយៈពេលនេះដែរ មេធាវីការពារក្តីត្រូវពង្រាង និងដាក់សំណើសុំបំពេញកិច្ចស៊ើបសួរថ្មី ដោយផ្អែកលើភស្តុតាងថ្មីទាំងនេះ។ ក្នុងការអនុវត្តជាក់ស្តែង ការនេះពិតជាមិនអាចធ្វើទៅបាននោះទេ[17]។ អាស្រ័យហេតុនេះ មេធាវីការពារក្តីនឹងត្រូវបានច្រានចេញពីការចូលរួមប្រកបដោយប្រសិទ្ធិភាព នៅក្នុងដំណើរការនីតិវិធី ដោយសារតែមេធាវីការពារមិនអាចធ្វើសំណើប្រកបដោយប្រសិទ្ធិភាពបានទេ ទាក់ទងទៅនឹងភស្តុតាងដែលបានដាក់បញ្ចូលទៅក្នុងសំណុំរឿងនៅដំណាក់កាលចុងក្រោយនេះ។

## គ. កាលបរិច្ឆេទបញ្ចប់កិច្ចស៊ើបសួរ មិនច្បាស់លាស់

---

[17] វាពិតណាស់មេធាវីការពារក្តីនឹងដាក់បណ្តឹងឧទ្ធរណ៍មួយចំនួន (ក្នុងរយៈពេលដ៏ខ្លីនេះ) ប្រឆាំងនឹងដីកាសម្រេចលើសំណើសុំបំពេញកិច្ចស៊ើបសួរ។

37. ក្រោមប្រព័ន្ធបច្ចុប្បន្ន មេធាវីការពារក្តីគ្មានមធ្យោបាយដើម្បីកំណត់ថា តើការជូនដំណឹងដោយ កសចស ដែលអនុញ្ញាតដោយវិធាន ៦៦ នឹងប្រព្រឹត្តទៅនៅពេលណាពិតប្រាកដនោះ[18]។ ភាពមិនប្រាកដប្រជានេះ អាចបង្កនូវការស្មុគស្មាញធ្ងន់ធ្ងរដល់ការងាររបស់មេធាវីការពារក្តី។ ក្រោមប្រព័ន្ធបច្ចុប្បន្ននេះ សិទ្ធិរបស់ជនជាប់ចោទអាចត្រូវបានរំលោភបំពាន បើសិន កសចស លាតត្រដាងលទ្ធផលចុងក្រោយបំផុតនៃកិច្ចស៊ើបសួររបស់ខ្លួន ដល់មេធាវីការពារក្តីនៅមុនការជូនដំណឹងក្រោមវិធាន ៦៦ នោះ។

38. មេធាវីការពារក្តីឈ្មុសឈ្មុលដាក់សំណើសុំបំពេញកិច្ចស៊ើបសួរទាំងអស់ឲ្យទាន់ពេលកំណត់។ ប៉ុន្តែដោយសារទំហំនៃរឿងក្តី និងធនធានកម្រិតរបស់មេធាវីការពារក្តី យើងមិនអាចព្យាករបានពីការដាក់សំណើជាក់លាក់នៅពេលណានោះទេ។ ហេតុដូចនេះ នៅថ្ងៃដាក់ការជូនដំណឹង មេធាវីការពារក្តីអាចកំពង់តែពង្រាង ឬ ពិចារណាលើសំណើបន្ថែម ក៏ថាបាន។

39. ម្យ៉ាងទៀត វាប្រាកដណាស់ថាលទ្ធផលច្រើនថែមទៀតនៃកិច្ចស៊ើបសួរនឹងដាក់បញ្ចូលទៅក្នុងសំណុំរឿង ដោយ កសចស នៅខែបន្តបន្ទាប់ខាងមុខនេះ។ នាសប្តាហ៍ថ្មីៗនេះ បង្ហាញពីការកើនឡើងថេរនៃការដាក់បញ្ចូលលទ្ធផលនៃកិច្ចស៊ើបសួរ ទៅក្នុងសំណុំរឿង។ វាមិនប្រាកដទេថាមេធាវីការពារក្តីនឹងសំអាងលើព័ត៌មាននៅក្នុងឯកសារទាំងនេះ ដើម្បីធ្វើសំណើបន្ថែមស្នើសុំកិច្ចស៊ើបសួរនោះទេ។

40. ដោយសារតែតថភាពទាំងនេះហើយ ទើបមេធាវីការពារក្តីមិនអាចធ្វើផែនការសកម្មភាពរបស់ខ្លួនប្រកបដោយប្រសិទ្ធិភាពនៅខែខាងមុខនេះបានទេ។ មេធាវីការពារក្តីពិតជាមិនដឹងថា តើមានភស្តុតាងអ្វីខ្លះដែលនឹងបន្តរកបាន ហើយថា តើត្រូវរៀបចំដាក់សំណើសុំបំពេញកិច្ចស៊ើបសួរថ្មីយ៉ាងដូចម្តេចនោះ។

---

[18] ពិតណាស់ វាកើតមាននៅក្នុងប្រព័ន្ធដែលកំពុងអនុវត្ត។ វាប្រាកដណាស់ថា ការជូនដំណឹងនេះនឹងក្រើនរំលឹកដល់មេធាវីការពារក្តីពីការស៊ើបសួរ ដែលមិនទាន់បញ្ចប់នៅឡើយ។ ហេតុនេះ មេធាវីការពារក្តីស្នើសុំនូវទម្រង់នៃការជូនដំណឹងជាមុន ដោយសារតែមេធាវីការពារប្រមើលជាមុនថាប្រព័ន្ធបច្ចុប្បន្ននេះ អាចបង្កការគ្រោះថ្នាក់ដល់សិទ្ធិរបស់ជនត្រូវចោទ។ ការយល់ (ក្រៅផ្លូវការ)របស់មេធាវីការពារ គឺថា កសចស "មានបំណង" ដាក់ការជូនដំណឹងពីវិធាន ៦៦ នៅខែធ្នូ ឆ្នាំ២00៩ ដែលមិនគ្រប់គ្រាន់ទេសម្រាប់គោលបំណងរៀបចំសកម្មភាពរបស់មេធាវីការពារក្តី។ មិនគ្រាន់តែរយៈពេលនេះមិនច្បាស់លាស់គ្រប់គ្រាន់នោះទេ តែគោលបំណងនៃកាលបរិច្ឆេទនឹងអាចត្រូវបានប្តូរ ដែលមេធាវីការពារមិនអាចដឹង។

41. រយៈពេល១៥ ថ្ងៃ មិនបានផ្តល់ឲ្យមេធាវីការពារក្តីនូវឱកាសគ្រប់គ្រាន់ ដើម្បីធ្វើពង្រាងសំណើបន្ថែម បើពិចារណាលើទំហំនៃសំណុំរឿងបច្ចុប្បន្ន ហើយភស្តុតាងថ្មីៗត្រូវបានបញ្ចូលទៅក្នុងសំណុំរឿងជាបន្តបន្ទាប់។ សកម្មភាពដទៃទៀតដែលមេធាវីការពារក្តីត្រូវបំពេញក្នុងរយៈពេល១៥ ថ្ងៃ (ដូចបានពិភាក្សាពីលើ ដូចជាលទ្ធភាពធ្វើពង្រាង និងដាក់បណ្តឹងឧទ្ធរណ៍ និងដាក់សំណើបន្ថែមដោយផ្អែកលើភស្តុតាងថ្មីដែលទើបរកបាន) ធ្វើឲ្យបញ្ហានេះកាន់តែធ្ងន់ធ្ងរតែប៉ុណ្ណោះ។

## ឃ. ភាពមិនអាចបកប្រែឲ្យបានទាន់ពេលវេលា

42. តម្រូវការបកប្រែពីភាសាអង់គ្លេសទៅភាសាខ្មែរ (ឬពីភាសាខ្មែរទៅជាភាសាអង់គ្លេស)នូវរាល់ឯកសារដែលមេធាវីការពារក្តីមានបំណងដាក់ គឺជាបញ្ហាដ៏ស្មុគស្មាញបំផុតសម្រាប់មេធាវីការពារក្តី។ ក្នុងរយៈពេល១៥ ថ្ងៃបន្ទាប់ពីការជូនដំណឹងក្រោមវិធាន ៦៦ អ្នកបកប្រែសំណេរត្រូវបកប្រែសំណើទាំងអស់ ស្នើសុំបំពេញកិច្ចស៊ើបសួរបន្ថែមដែលអាចដាក់ដោយក្រុមការពារក្តីទាំងអស់។ ម្យ៉ាងទៀត ប្រសិនបើសេចក្តីសម្រេចលើសំណើសុំបំពេញកិច្ចស៊ើបសួរដែលមិនទាន់សម្រេច ផ្សព្វផ្សាយដំណាលគ្នានឹងការជូនដំណឹង (ឬភ្លាមៗនៅមុនរយៈពេលហ្នឹង) នោះអ្នកបកប្រែត្រូវបកប្រែសារណាបណ្តឹងឧទ្ធរណ៍ទាំងអស់ ដែលអាចដាក់ដោយក្រុមការពារក្តីទាំងអស់ក្នុងរយៈពេល៣០ថ្ងៃបន្ទាប់ពីការជូនដំណឹងនោះ។ សូមកត់សំគាល់ថា អ្នកបកប្រែភាសាអាចចាប់ផ្តើមបកប្រែបានលុះត្រាតែឯកសារដើមត្រូវបានធ្វើរួចរាល់ ដែលត្រូវប្រើពេលបន្ថែមជាច្រើនថ្ងៃដែរ នេះបណ្តាលឲ្យបាត់បង់ពេលវេលាបន្ថែមទៀតដល់អ្នកបកប្រែ។

43. ពុំមានមធ្យោបាយណាដែលអាចព្យាករពីចំនួនបណ្តឹងឧទ្ធរណ៍ និងពីចំនួនសំណើសុំបំពេញកិច្ចស៊ើបសួរ ដែលដាក់ដោយមេធាវីការពារក្តីបានឡើយ។ ប៉ុន្តែ វាប្រាកដណាស់ថា ប្រសិនបើបណ្តឹងឧទ្ធរណ៍ និងសំណើសុំបំពេញកិច្ចស៊ើបសួរបន្ថែមមានចំនួនច្រើន នោះក្រុមអ្នកបកប្រែពិតជាមិនអាចបំពេញកិច្ចការបែបនេះ នៅក្នុងពេលវេលាដែលផ្តល់ឲ្យនោះបានទេ។ តថភាពនេះ បញ្ជាក់ពីសេចក្តីត្រូវការផ្សព្វផ្សាយឲ្យទាន់ពេលវេលា នូវសេចក្តីសម្រេចលើសំណើសុំបំពេញកិច្ចស៊ើបសួរ និងលទ្ធផលថ្មីៗនៃកិច្ចស៊ើបសួរដោយ កសចស។

## ង. ព័ត៌មានសាវតារនៃប្រព័ន្ធដែលអនុម័តនៅក្នុងវិធានផ្ទៃក្នុង

44. នៅពេលពិចារណាលើសំណើនេះ វាជាការសំខាន់ក្នុងការសង្កេតថា ប្រព័ន្ធនេះត្រូវបានបង្កើតនៅក្នុងវិធាន ៦៦ (រយៈពេល១៥ ថ្ងៃដើម្បីដាក់សំណើបន្ថែម បន្ទាប់ពីជូនដំណឹងពីបញ្ចប់កិច្ចស៊ើបសួរ)

គឺសំអាងលើការបកស្រាយក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា។ មាត្រា ២៤៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ចែងថា ព្រះរាជអាជ្ញាមានរយៈវេលា១៥ថ្ងៃ ដើម្បីដាក់សំណើសុំបំពេញកិច្ចស៊ើបសួរបន្ថែម[19]។ ក្នុងការប៉ុនប៉ងបង្កើតប្រព័ន្ធច្បាប់មួយដែលផ្តល់សិទ្ធិស្មើៗគ្នាដល់មេធាវីការពារក្តី អ្នកពង្រាងវិធាន ផ្ទៃក្នុងបានប្រែក្លាយបទបញ្ញត្តិច្បាប់នេះ ទៅក្នុងប្រព័ន្ធមួយដែលអាចរកឃើញនៅក្នុងវិធាន ៦៦ ដែលមេធាវីការពារក្តីមានសិទ្ធិដូចគ្នានឹងព្រះរាជអាជ្ញាដែរ។

45. វាច្បាស់ណាស់ថា ប្រព័ន្ធដែលបង្កើតដោយក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា មិនអាចអនុវត្តបានទៅលើប្រភេទនៃកិច្ចស៊ើបសួរ និងទំហំនៃរឿងក្តីរបស់ **នួន ជា** នោះទេ។ រយៈពេល១៥ ថ្ងៃអាចគ្រប់គ្រាន់សម្រាប់ដំណើរការនីតិវិធីរឿងក្តីព្រហ្មទណ្ឌធម្មតានៅកម្ពុជា ប៉ុន្តែ សម្រាប់ដំណើការនីតិវិធីបច្ចុប្បន្ន ដោយសារតែងទំហំ និងលក្ខណៈពិសេសរបស់វា ថេរវេលានេះគឺខ្លីណាស់ ។

46. ពិសេស ប្រព័ន្ធដែលផ្តល់ដោយមាត្រា ២៤៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា ហាក់ដូចជាសន្មតថា ចៅក្រមស៊ើបអង្កេតបានសម្រេចលើសំណើមុនៗទាំងអស់របស់ព្រះរាជអាជ្ញា នៅពេលជូនដំណឹងបញ្ចប់កិច្ចស៊ើបសួរ[20]។ ការសន្និដ្ឋាននេះទាញចេញការសង្កេតដែលថា មាត្រា ២៤៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌ មិនមានប្បញ្ញត្តិដែលប្រហាក់ប្រហែលនឹងវិធាន ៦៦(២) ប្រយោគទី២ទាំងមូល[21]។

47. ការសង្កេតនេះផ្តល់ការគាំទ្របន្ថែមចំពោះជំហរដែលថា ការសម្រេចលើសំណើដែលដាក់តាំងពីពេលដំបូងនៃកិច្ចស៊ើបសួរ ត្រូវតែបានសម្រេចភ្លាមៗ ដើម្បីផ្តល់ឱកាសដល់មេធាវីការពារក្តីឆ្លើយតបឱ្យបានសមស្របចំពោះលទ្ធផលនៃសំណើទាំងនេះ (ដោយដាក់បណ្តឹងឧទ្ធរណ៍សំណើសុំបំពេញកិច្ចស៊ើបសួរបន្ថែម ឬ ទទួលយកលទ្ធផលនៃការស៊ើបសួរ)។

## ច. ការពិចារណាជាប្រព័ន្ធ

48. ការកែលំអប្រព័ន្ធដែលស្នើឡើងដោយមេធាវីការពារក្តី គឺស្របជាមួយប្រព័ន្ធស៊ើបសួរដែលអ្នកពង្រាងវិធានផ្ទៃក្នុងមាននៅក្នុងចិត្ត ហើយប្រព័ន្ធដែលស្នើនេះមានច្រើនជាងរចនាសម្ព័ន្ធបច្ចុប្បន្នទៅទៀត។

---

[19] ថេរវេលា១៥ ថ្ងៃសម្រាប់ព្រះរាជអាជ្ញា ចែងមិនច្បាស់ទេនៅក្នុងមាត្រា ២៤៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា, ប៉ុន្តែ ន័យនេះចេញពីវាក្យសព្ទ និងរចនាសម្ព័ន្ធនៃមាត្រានេះ។

[20] ព្រះរាជអាជ្ញាដាក់សំណើសុំបំពេញកិច្ចស៊ើបសួរ ។ សូមមើលមាត្រា ១៣២ នៃក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា។

[21] សូមមើលវិធាន ៦៦ (២) (“ដីកានេះត្រូវបដិសេធផងដែរនូវរាល់សំណើទាំងអស់ ដែលបានដាក់តាំងពីពេលដំបូងនៃកិច្ចសួរ ដែលខ្លួនមិនទាន់សម្រេចនៅឡើយ។

00401533



49. ដូចបានចែងនៅក្នុងវិធានផ្ទៃក្នុង ដំណើរការនីតិវិធីនៅចំពោះមុខ អវតក ព្យាករពីដំណាក់កាលស៊ើបសួរមួយដែលធំទូលាយនិងគ្រប់ជ្រុងជ្រោយ(វិធាន ៥៥-៧០) បន្ទាប់មកគឺដំណាក់កាលសវនាការបន្ទាប់ពីកិច្ចស៊ើបសួរបានបញ្ចប់ទាំងស្រុង[22]។ វាពិតណាស់ថា អង្គជំនុំជម្រះសាលាដំបូងអាចបង្គាប់ឱ្យស៊ើបសួរបន្ថែម[23] ហើយវាកាន់តែច្បាស់ថែមទៀតនោះ ប្រព័ន្ធនេះចង់ឱ្យបញ្ចប់កិច្ចស៊ើបសួរ នៅមុនដំណាក់កាលសវនាការ។ ការគាំទ្រជាក់ស្តែងបំផុតដល់ការអះអាងនេះ កើតចេញពីតួនាទីដ៏មានសារៈសំខាន់នៃការិយាល័យរបស់លោក។

50. សេចក្តីសន្និដ្ឋាននេះទាញចេញពីតួនាទីរបស់ កសចស និង អង្គជំនុំជម្រះសាលាដំបូង។ ពិតជាមិនអាចប្រកែកបានទេថា ការិយាល័យសហចៅក្រមស៊ើបអង្កេត គឺជាស្ថាប័នមួយរបស់ អវតក ដែលស័ក្តិសមបំផុតក្នុងការដឹកនាំការស៊ើបសួរ ដែលបានដំណើរការប៉ុន្មានឆ្នាំមកនេះ។ កសចស បានបង្កើតវិធីសាស្ត្រធ្វើការ ហើយទទួលបានជំនាញស៊ើបសួរដ៏ច្រើនសន្ធឹកសន្ធាប់[24]។ ម្យ៉ាងវិញទៀត អង្គជំនុំជម្រះសាលាដំបូងពុំមានបទពិសោធខាងការស៊ើបសួរនេះទេ។ អាស្រ័យហេតុនេះ កិច្ចស៊ើបសួរត្រូវតែធ្វើឡើង*ប្រកបដោយប្រសិទ្ធិភាព* ដោយ កសចស មិនមែនដោយសមាជិកណាម្នាក់នៃអង្គជំនុំជម្រះសាលាដំបូងឡើយ។

51. ប្រសិនបើការស៊ើបសួរដែលធ្វើឡើងដោយការិយាល័យរបស់លោកនៅពេលក្រោយ នៅដំណាក់កាលសវនាការ នោះការស៊ើបសួរនេះនឹងមិនមានលក្ខណៈទូលំទូលាយ និងគ្រប់ជ្រុងជ្រោយទេ ហើយការស៊ើបសួរបន្ថែមនេះ អាចត្រួតពិនិត្យដោយសមាជិកណាម្នាក់នៃអង្គជំនុំជម្រះសាលាដំបូងជាជាង កសចស។ ដូចបានរៀបរាប់រួចមកហើយ អង្គជំនុំជម្រះសាលាដំបូងមិនមានបទពិសោធន៍ពាក់ព័ន្ធជាមួយការស៊ើបសួរនោះទេ។ ហេតុដូចនេះ ការស៊ើបសួរនឹងត្រូវប្រើពេលវេលាច្រើន ហើយអាចជាការស៊ើបសួរមានគុណភាពទាបទៀតផង។ សម្រាប់មូលហេតុសេដ្ឋកិច្ចតុលាការ និងដោយពិចារណាពីតម្រូវការនូវការជំនុំជម្រះក្តីដោយយុត្តធម៌ ការស៊ើបសួរនេះមិនស័ក្តិសមឡើយ។

---

[22] វិធានផ្ទៃក្នុង ៥៥-៧០ ។

[23] វិធាន ៩៣ នៃវិធានផ្ទៃក្នុង ។

[24] ប៉ុន្តែ ភាពស្រអាប់វិធីសាស្ត្រនេះកើតមាននៅក្នុងក្រុមការពារក្តី ។ ឧទាហរណ៍សូមមើលសំណើលើកទី៣ ស្នើសុំបំពេញកិច្ចស៊ើបសួររបស់ អៀង សារី ចុះថ្ងៃទី ២១ ខែឧសភា ២០០៩, ឯកសារ D171 ។

52. ប្រហែលជាអង្គជំនុំជម្រះសាលាដំបូងនឹងព្យាយាម“បញ្ជូន”ចំណោទជាក់លាក់មក កសចស វិញ។ វាមិនច្បាស់ទាំងស្រុងថា តើវិធាន៩៣ ផ្តល់អំណាចនេះដល់អង្គជំនុំជម្រះសាលាដំបូងដែរ ឬយ៉ាងណានោះទេ[25]។ ប្រសិនបើអង្គជំនុំជម្រះសាលាដំបូងដើរតាមគន្លងនេះមែន និងបញ្ជូនកិច្ចស៊ើបសួរជាក់លាក់ត្រឡប់មក កសចស វិញ នោះការិយាល័យនេះប្រហែលជាបានកាត់បន្ថយចំនួនបុគ្គលិកបន្ទាប់ពីចេញដីកាដំណោះស្រាយ។ សមត្ថភាពរបស់ កសចស ក្នុងការដឹកនាំកិច្ចស៊ើបសួរនឹងត្រូវកាត់បន្ថយដែរ។ ជំនាញខាងស៊ើបសួរដ៏ធំក្នុងសង្គមកម្ពុជាបច្ចុប្បន្ននឹងត្រូវបាត់បង់ ដែលបណ្តាលមកពីការបន្ថយចំនួនបុគ្គលិក ដែលអាចជាការជំរុះបុគ្គលចោលជារៀងរហូត[26]។ ការពិចារណានេះបង្កើតជាទឡ្ហីករណ៍បន្ថែម ដើម្បីដំណើការស៊ើបសួរឲ្យបានច្រើន តាមតែអាចធ្វើទៅបានក្នុងដំណាក់កាលស៊ើបអង្កេតនេះ[27]។

53. មូលហេតុចុងក្រោយដើម្បីធ្វើការស៊ើបសួរឲ្យបានច្រើន តាមតែអាចធ្វើទៅបាន នៅដំណាក់កាលស៊ើបសួរនេះ អាចត្រូវបានគេយល់ថា ការស៊ើបសួរបឋមដែលមិនគ្រប់ជ្រុងជ្រោយ នឹងប៉ះពាល់ដល់ដំណើរការនីតិវិធីសវនាការ។ ជាបឋម បើទោះបីជាមានការដាក់សំណើសុំបំពេញកិច្ចស៊ើបសួរច្រើនដោយមេធាវីការពារក្តី ផ្អែកតាមការសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង ក៏នឹងមានការរំខានដល់ដំណើរការនីតិវិធីសវនាការដែរ។ ទី២ ការយល់ព្រមលើសំណើជាក់លាក់ នឹងនាំទៅរកការពន្យារពេលនៅក្នុងដំណើរការនីតិវិធីជៀសពុំរួចឡើយ (វាអាចការជាពន្យារពេលយូរទៀតផង)។ អាស្រ័យហេតុនេះ សម្រាប់មូលហេតុសេដ្ឋកិច្ចតុលាការ កិច្ចស៊ើបសួរបឋមត្រូវតែទូលំទូលាយ និងគ្រប់ជ្រុងជ្រោយ តាមតែអាចធ្វើបាន។

54. ការសង្កេតទាំងនេះបង្ហាញយ៉ាងច្បាស់ថា ប្រព័ន្ធដែលត្រូវបានបង្កើតឡើងនេះមានបំណងឲ្យកិច្ចស៊ើបសួរបឋមមួយ ពេញលេញ និងគ្រប់ជ្រុងជ្រោយ។ នេះមានន័យថា សំណើសុំបំពេញកិច្ចស៊ើបសួររបស់មេធាវីការពារក្តី រួមទាំងសំណើដែលបានដាក់រួចមកហើយ និងសំណើដែលនឹងដាក់នៅពេលអនាគត ត្រូវតែបានដោះស្រាយឲ្យបានពេញលេញ និងគ្រប់ជ្រុងជ្រោយ នៅដំណាក់ស៊ើបសួរនេះ ដើម្បីបញ្ចៀសការពន្យារពេលនៅដំណាក់កាលសវនាការ។

---

[25] តាមការអានវិធាន ៩៣ មិនអាចសន្និដ្ឋានជាមុន។ សូមកត់សំគាល់ថា មេធាវីការពារក្តីមិនមានជំហរលើបញ្ហានេះនៅពេលនេះទេ

[26] វាទំនងថាទាំងអ្នកស៊ើបអង្កេត និង មន្ត្រីច្បាប់ នឹងស្វែងរកការងារនៅទីកន្លែងផ្សេង។

[27] ជម្រើស នៅក្នុងស្ថានការដែលកិច្ចស៊ើបសួរសម្រាប់សំណុំរឿង ០០៣ ដែលនឹងដំណើរការនៅពេលបន្ទាប់ដោយអង្គជំនុំជម្រះសាលាដំបូង និង កសចស ត្រូវមានកំលាំងគ្រប់គ្រាន់ដើម្បីធ្វើការស៊ើបសួរទៅលើអង្គហេតុនៅក្នុងករណីនោះ កសចស នឹងមិនមានធនធានគ្រប់គ្រាន់ ដើម្បីចាត់តាំងធនធានមនុស្សដើម្បីប្រតិបត្តសំណើសុំបំពេញកិច្ចស៊ើបសួរលើសំណុំរឿង ០០២ នោះទេ។

## V.សេចក្តីសន្និដ្ឋាន

55. មេធាវីការពារក្តីព្រួយបារម្ភពីការខ្វះចន្លោះយ៉ាងធ្ងន់ធ្ងរនៅជុំវិញ (ការជូនដំណឹង) ការបញ្ចប់កិច្ចស៊ើបសួរ ដែលនាំទៅរកការរំលោភសិទ្ធិរបស់កូនក្តីយើងខ្ញុំ ក្នុងការទទួលបានការជំនុំជម្រះក្តីដោយយុត្តិធម៌។ គោលបំណងរបស់សំណើនេះ គឺដើម្បីកែលំអនូវចំនុចខ្វះចន្លោះទាំងនេះ។

56. បើសិន កសចស មានផែនការស៊ើបសួរតាមការស្នើសុំរបស់យើង នោះមេធាវីការពារក្តីសូមឱ្យ កសចស បញ្ជាក់ពីគោលជំហរនេះឱ្យបានឆាប់។ មេធាវីការពារក្តីកត់សំគាល់ថា សំណើនេះមិនបានស្នើឱ្យបំពេញកិច្ចស៊ើបសួរដែលប្រើពេលវេលានោះទេ ប៉ុន្តែសំណើនេះស្នើសុំការឆ្លើយតបភ្លាមៗទៅនឹងសំណើជាក់លាក់មួយចំនួន។

57. ដូចមានមូលហេតុដែលបញ្ជាក់នៅទីនេះ និងស្របតាមកម្មវត្ថុនៃសំណើនេះ (ពេលវេលាប្រថុចញ៉ុកសម្រាប់មេធាវីការពារក្តី) មេធាវីការពារក្តីស្នើសុំការឆ្លើយតបពីការិយាល័យរបស់លោកក្នុងរយៈពេលពី(២)សប្តាហ៍ បន្ទាប់ពីបានទទួលលិខិតនេះ ។ ចម្លើយរបស់លោកនឹងប៉ះពាល់ជៀសមិនផុតដល់ការធ្វើផែនការសកម្មភាពរបស់យើងនៅប៉ុន្មានខែបន្តបន្ទាប់នេះ។

## VI.សំណូមពរ

58. អាស្រ័យហេតុនេះ ដើម្បីធានាដល់ការផ្តល់ “ពេលវេលានិងលក្ខណៈគ្រប់គ្រាន់” ដើម្បីមាន “ឥទ្ធិពលលើលទ្ធផលនៃដំណើរការនីតិវិធី” ប្រកបដោយប្រសិទ្ធិភាព មេធាវីការពារក្តីសូមស្នើដល់ កសចស:

ក. ជូនដំណឹងដល់ភាគីទាំងអស់ឱ្យបានឆាប់បំផុត តាមតែអាចធ្វើបាន ក្នុងរយៈពេលយ៉ាងយូរបំផុត**ពីរខែ** មុនពេលដាក់ការជូនដំណឹងពីកាលបរិច្ឆេទពិតប្រាកដ ដែល កសចស មានផែនការដាក់ការជូនដំណឹង ស្របតាមវិធាន ៦៦ ។

ខ. ដាក់បញ្ចូលលទ្ធផលថ្មីទាំងអស់នៃការស៊ើបសួរទៅក្នុងសំណុំរឿង ក្នុងរយៈពេលយ៉ាងខ្លីបំផុត**ពីរខែ** មុនពេលដាក់ការជូនដំណឹង ស្របតាមវិធាន ៦៦។ ក្របខណ្ឌពេលវេលានេះគឺសំខាន់ចាំបាច់ ដើម្បីធានាដល់ការចូលរួមនៅក្នុងនីតិវិធីប្រកបដោយប្រសិទ្ធិភាពពីសំណាក់ជនជាប់ចោទ។

គ. សម្រេចលើសំណើសុំបំពេញកិច្ចស៊ើបសួរដែលមិនទាន់សម្រេចទាំងអស់ ក្នុងរយៈពេលយ៉ាងខ្លីបំផុត**ពីរខែ** មុនពេលដាក់ការជូនដំណឹង ស្របតាមវិធាន ៦៦។ ក្របខណ្ឌពេលវេលា

ឯកសារ២៣៥



នេះ គឺសំខាន់ចាំបាច់ ដើម្បីធានាដល់ការចូលរួមនៅក្នុងនីតិវិធីប្រកបដោយប្រសិទ្ធិភាព ពីសំណាក់ជនជាប់ចោទ។

ឃ. ឆ្លើយតបចំពោះសំណើនេះក្នុងរយៈពេលពីរ (២) សប្តាហ៍ បន្ទាប់ពីបានដាក់។

សហមេធាវីរបស់លោក **នួន ជា**

| | | | |
|---|---|---|---|
| ថ្ងៃទី៥ ខែវិច្ឆិកា ឆ្នាំ២០០៩ | **សុន អរុណ** | ភ្នំពេញ | |
| | **Michiel PESTMAN**<br>**Victor KOPPE** | ភ្នំពេញ | |
| កាលបរិច្ឆេទ | ឈ្មោះ | ទីកន្លែង | ហត្ថលេខា |